សាលាដំបូងខេត្តកំពត

*******

សាលក្រមព្រហ្មទណ្ឌលេខ:៦១"ញ"

ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣

សំណុំរឿងព្រហ្មទណ្ឌលេខ:៣៦

ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១១

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពត

បានបើកសវនាការជាសាធារណៈនៅសាលសវនាការនៃសាលាដំបូងខេត្តកំពត។

–កាលបរិច្ឆេទបើកសវនាការ: ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ វេលារសៀល។

–កាលបរិច្ឆេទប្រកាសសាលក្រម: ថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ វេលាព្រឹក។

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូង

**តំណាងអយ្យការ**

លោក [redacted] ហៅនៈព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

កញ្ញា [redacted] ក្រឡាបញ្ជីសាលាដំបូង

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ:៣៦ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១១ ដែលមានជនជាប់ចោទ:

១-ឈ្មោះ [redacted] ចេង ភេទស្រី អាយុ៨៥ឆ្នាំ ជាតិខ្មែរ មុខរបរជភ ។ ទីកន្លែងកំណើតភូមិអង្គោល ឃុំភ្នំលាវ ស្រុកកំពង់ត្រាច ខេត្តកំពត។ទីលំនៅបច្ចុប្បន្ន [redacted] ស្រុកដំណាក់ចង្អើរ ខេត្តកែប។ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted](ស) ប្ដីឈ្មោះ [redacted] មានកូន០១នាក់។ ទោសពីមុនគ្មាន។(ក្រៅឃុំ)

២-ឈ្មោះ [redacted]ហ៊ាន ភេទស្រី អាយុ៧៥ឆ្នាំ ជាតិខ្មែរ។ទីកន្លែងកំណើតភូមិអង្គោល ឃុំភ្នំលាវ ស្រុកកំពង់ត្រាច ខេត្តកំពត។ទីលំនៅបច្ចុប្បន្ន [redacted] ស្រុកដំណាក់ចង្អើរ ខេត្តកែប ។ ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted](ស) ប្ដីឈ្មោះ [redacted] មានកូន០៤នាក់។ទោសពីមុនគ្មាន។

ត្រូវជាប់ចោទពីបទ លក់អចលនវត្ថុអ្នកដទៃ។ ប្រព្រឹត្តនៅភូមិអង្គោល ឃុំអង្គោល ស្រុកដំណាក់ចង្អើរ ខេត្តកែប កាលពីថ្ងៃទី០១-១០-២០០៧។បទល្មើសព្រហ្មទណ្ឌ និងទោសមានចែងក្នុង មាត្រា ២៥៥ នៃច្បាប់ភូមិបាល។

៣-ឈ្មោះ [redacted] ឆាយ ហៅពែក ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ មុខរបរនេសាទ ។ ទីកន្លែងកំណើតភូមិអង្គោល សង្កាត់អង្គោល ខណ្ឌដំណាក់ចង្អើរ ក្រុងកែប។ទីលំនៅបច្ចុប្បន្ន [redacted] អង្គោល ស្រុកដំណាក់ចង្អើរ ខេត្តកែប។ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted]) មានកូនបីនាក់។ ទោសពីមុនគ្មាន។(ក្រៅឃុំ)

មានលោក [redacted] សាកល ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

៤-ឈ្មោះ [redacted]ឯម ភេទប្រុស អាយុ៦៨ឆ្នាំ ជាតិខ្មែរ មុខរបរសមាជិកក្រុមប្រឹក្សាឃុំ ។ ទីកន្លែងកំណើតភូមិអង្គោល ឃុំភ្នំលាវទី២ ស្រុកកំពង់ត្រាច ខេត្តកំពត។ ទីលំនៅបច្ចុប្បន្ន [redacted] ស្រុកដំណាក់ចង្អើរ ខេត្តកែប ។ ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] (ស) មានកូនបួននាក់។ ទោសពីមុនគ្មាន។(ក្រៅឃុំ)

ត្រូវជាប់ចោទពីបទក្លែងបន្លំលិខិត។ប្រព្រឹត្តនៅភូមិអង្គោល ឃុំអង្គោល ស្រុកដំណាក់ចង្អើរ ខេត្ត



Scanned by CamScanner

កែប កាលពីថ្ងៃទី០១-១០-២០០៧។បទល្មើសក្រមព្រហ្មទណ្ឌ និងទោសមានចែងក្នុង មាត្រា ៦២៦ និងមាត្រា ៦២៧ នៃ ក្រមព្រហ្មទណ្ឌ។

តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ: ៣៦០ ចុះថ្ងៃទី២២-០១-២០១៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកំពត។

**ដើមបណ្តឹងរដ្ឋប្បវេណី**

ឈ្មោះ: [redacted] ភេទស្រី អាយុ៧៧ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិត្រពាំងរៀល ឃុំឫស្សីស្រុកខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត។

មានលោក [redacted]សូត្រ ជាមេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី។

**ឯកត្តហេតុកើតមានឡើងដូចតទៅ:**ឈ្មោះ:[redacted]ហៀវ បានកាន់កាប់ដីមួយកន្លែងស្ថិតនៅភូមិអង្គោល ឃុំអង្គោល ស្រុកដំណាក់ចង្អើរ ខេត្តកែប តាំងពីឆ្នាំ១៩៧៩ មក។នៅក្នុងឆ្នាំ១៩៨៣ ឈ្មោះ[redacted]ហៀវ បានចាកចេញទៅរស់នៅឯស្រុកកំពង់ត្រាច ខេត្តកំពត បានឲ្យឈ្មោះ: [redacted]សិដ្ឋ ជាអ្នកជួយមើលថែ និងបង្កបង្កើតផលលើដីនោះ។លុះមកដល់ឆ្នាំ២០០៧ ស្រាប់តែឈ្មោះ[redacted]ចេង និងឈ្មោះ[redacted]ហ៊ាន បានយកដីនោះលក់ទៅឲ្យឈ្មោះ[redacted] ឆាយ ហៅពែក និងបានឃុបឃិតគ្នាជាមួយឈ្មោះ: [redacted]ឯម ក្លែងមេដៃលោកមេភូមិអង្គោល លើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី ចុះថ្ងៃទី០១-១០-២០០៧ ដើម្បីទិញយកដីនោះ។

**នាពេលសវនាការ**

**ក្រោយពីបាន:**

-ស្តាប់ និងសួរចម្លើយជនជាប់ចោទឈ្មោះ[redacted]ចេង
-ស្តាប់ និងសួរចម្លើយជនជាប់ចោទឈ្មោះ[redacted]ឆាយ ហៅពែក
-ស្តាប់ និងសួរចម្លើយជនជាប់ចោទឈ្មោះ:[redacted]ឯម
-អានចម្លើយជនជាប់ចោទឈ្មោះ: [redacted] ហ៊ាន
-ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ: [redacted] ហៀវ
-ស្តាប់ចម្លើយសាក្សីឈ្មោះ: [redacted]សិ
-ស្តាប់អំណានឯកសារ និងកំណត់ហេតុផ្សេងៗទៀតមាននៅក្នុងសំណុំរឿង
-ស្តាប់មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានការពារ
-ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់លោកតំណាងអយ្យការ
-ស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
-ស្តាប់ជនជាប់ចោទធ្វើសំណូមពរជាសំដីចុងក្រោយ
-ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

១.តាមការពិនិត្យភស្តុតាង និងតាមរបាយការណ៍របស់ស្នងការដ្ឋាននគរបាលឃើញថា:ឈ្មោះ:[redacted] ហៀវ បានកាន់កាប់ដីមួយកន្លែងស្ថិតនៅភូមិអង្គោល ឃុំអង្គោល ស្រុកដំណាក់ចង្អើរ ខេត្តកែប តាំងពីឆ្នាំ១៩៧៩ មក។នៅក្នុងឆ្នាំ១៩៨៣ ឈ្មោះ:[redacted]ហៀវ បានចាកចេញទៅរស់នៅឯស្រុកកំពង់ត្រាច ខេត្តកំពត បានឲ្យឈ្មោះ:[redacted] សិដ្ឋ ជាអ្នកជួយមើលថែ និងបង្កបង្កើតផលលើដីនោះ។លុះមកដល់ឆ្នាំ២០០៧ ស្រាប់តែឈ្មោះ: [redacted] ចេង និងឈ្មោះ:[redacted] ហ៊ាន បានយកដី នោះលក់ទៅឲ្យឈ្មោះ[redacted] ឆាយ ហៅ[redacted] និងបានឃុបឃិតគ្នាជាមួយឈ្មោះ: [redacted]ឯម ក្លែងមេដៃលោកមេភូមិអង្គោល លើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី ចុះថ្ងៃទី០១-១០-២០០៧ ដើម្បីទិញយកដីនោះ។

២.យោងភស្តុតាងជាក់បន្ទុកមាន:

-តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា:កាលពីឆ្នាំ១៩៧៩ខ្លួននិងប្តីបានរស់នៅនិងកាន់កាប់ដីមួយកន្លែងស្ថិតនៅភូមិអង្គោល ឃុំអង្គោល ស្រុកដំណាក់ចង្អើរ ខេត្តកែប តាំងពីឆ្នាំ១៩៧៩ មក។នៅក្នុងឆ្នាំ១៩៨៣ ឈ្មោះ:[redacted]ហៀវ បានចាកចេញទៅរស់នៅឯស្រុកកំពង់ត្រាច ខេត្តកំពត បានឲ្យឈ្មោះ:



Scanned by CamScanner

[redacted]សិដ្ឋ ជាក្មួយជួយមើលថៃ និងបង្កបង្កើតផលលើដីនោះ នៅឆ្នាំ២០០៧ ទើបទទួលដំណឹងថា:ឈ្មោះ [redacted]ចេង និងឈ្មោះ[redacted]ហ៊ាន បានលួចលក់ដីរបស់ខ្លួន ។

-តាមចម្លើយរបស់សាក្សីឈ្មោះ[redacted]លិ បានឆ្លើយថា: ឈ្មោះ[redacted]ឆាយ ហៅពែក បានប្រើខ្លួនឲ្យធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លីដែលបានទិញដីពីឈ្មោះ:[redacted]ចេង និងឈ្មោះ:[redacted]ហ៊ាន ហើយខ្លួនបានយកលិខិតនេះឲ្យមេភូមិផ្តិតមេដៃ តែលោកមេភូមិមិនបានផ្តិតមេដៃទេ ពេលត្រលប់មកវិញបានជួបឈ្មោះ:[redacted]ឯម កំពុងអង្គុយហូបនំ និងពិនិត្យលិខិតនោះរួច គាត់បានផ្តិតមេដៃជំនួសឈ្មោះ:[redacted]សុន តែម្តង។

-តាមចម្លើយរបស់សាក្សីឈ្មោះ[redacted]សុន បានឆ្លើយថា:លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី ចុះថ្ងៃទី០១-១០-២០០៧ មិនមែនជាស្នាមមេដៃរបស់ខ្លួន ហើយខ្លួនក៏មិនបានផ្តិតមេដៃលើលិខិតនោះដែរ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted]ចេង និងឈ្មោះ:[redacted]ហ៊ានបានឆ្លើយថា:ដីនេះខ្លួនបានគ្រប់គ្រងតាំងពីឆ្នាំ១៩៧៩ តែពុំមានលិខិតស្នាមអ្វីទាំងអស់ ក្រោយមកឈ្មោះ:[redacted]ចេក ឈីខ្លួនបានលក់ដីនេះឲ្យឈ្មោះ[redacted]ឆាយ ហៅពែក ដើម្បីព្យាបាលជម្ងឺ ។ចំណែកការធ្វើសំណុំឯកសារខ្លួនពុំបានដឹងទេ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ: [redacted]ឆាយ ហៅពែក បានឆ្លើយថា:ខ្លួនពិតជាបានទិញដីនេះពីឈ្មោះ:[redacted] ចេង និងឈ្មោះ:[redacted]ហ៊ាន និងបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី ដែលឈ្មោះ:[redacted]លិ ជាអ្នករត់ការធ្វើ និងបានប្រាប់ថា:ស្នាមមេដៃមេភូមិជាស្នាមមេដៃរបស់ឈ្មោះ:[redacted]ឯម ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ: [redacted]ឯម បានឆ្លើយសារភាពថា:ខ្លួនពិតជាបានពិនិត្យមើលលិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី ដែលធ្វើឡើងរវាងឈ្មោះ[redacted]ចេង និងឈ្មោះ:[redacted]ហ៊ាន និងឈ្មោះអ៊ឹង [redacted] ហៅពែក និងពិតជាបានផ្តិតមេដៃជំនួសលោកមេភូមិ[redacted]សុន លើពាក្យផ្ទេរសិទ្ធិកាន់កាប់ដីធ្លីពិតប្រាកដមែន ។

៣.ផ្អែកតាមភស្តុតាងដាក់បន្ទុកខាងលើ មានភាពស៊ីសង្វាក់គ្នា អាចកំណត់បានថា:

-ជនជាប់ចោទឈ្មោះ:[redacted]ចេង និងឈ្មោះ: [redacted] ហ៊ាន ពិតជាបានយកដីរបស់អ្នកដទៃលក់។ ឈ្មោះ:[redacted]ឆាយ ហៅពែក និងឈ្មោះ[redacted]ឯម ពិតជាបានក្លែងបន្លំលិខិត។

៤.មានភស្តុតាងកំណត់ពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ:[redacted]ចេង និងឈ្មោះ:[redacted] ហ៊ាន ពីបទលក់អចលនវត្ថុអ្នកដទៃ។ ឈ្មោះ:[redacted]ឆាយ ហៅពែក និងឈ្មោះ:[redacted]ឯម ពីបទក្លែងបន្លំលិខិត ប្រព្រឹត្តនៅភូមិអង្គោល ឃុំអង្គោល ស្រុកដំណាក់ចង្អើរ ខេត្តកែប កាលពីថ្ងៃទី០១-១០-២០០៧។បទល្មើសព្រហ្មទណ្ឌ និងទោសមានចែងក្នុងមាត្រា ២៥៥ នៃច្បាប់ភូមិបាល និងមាត្រា ៦២៦ និងមាត្រា ៦២៧ នៃក្រមព្រហ្មទណ្ឌ។

៥.<u>អំពីការប្រកាសទោស:</u> គប្បីប្រកាសទោសដាក់ពន្ធនាគារក្នុងកំរិតអប្បបរមា និងឲ្យព្យួរការអនុវត្តទោសទាំងមូលដោយហេតុថាព្យសនកម្មដែលកើតឡើងមិនមានភាពធ្ងន់ធ្ងរនោះទេ។ជនជាប់ចោទបានទទួលស្គាល់កំហុសរបស់ខ្លួន ។ ជនជាប់ចោទទើបតែបានប្រព្រឹត្តបទល្មើសដែលត្រូវផ្តន្ទាទោសជាលើកទីមួយ ហើយទោសដែលត្រូវប្រកាសមានរយៈពេលមិនលើសពីប្រាំឆ្នាំ យោងតាមមាត្រា១០៤. ១០៧ នៃក្រមព្រហ្មទណ្ឌ។

៦.មានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ:[redacted]ចេង និងឈ្មោះ:[redacted] ហ៊ាន ពីបទ លក់អចលនវត្ថុអ្នកដទៃ។ ឈ្មោះ: [redacted]ឆាយ ហៅពែក និងឈ្មោះ:[redacted] ឯម ពីបទក្លែងបន្លំលិខិត ប្រព្រឹត្តនៅភូមិអង្គោល ឃុំអង្គោល ស្រុកដំណាក់ចង្អើរ ខេត្តកែប កាលពីថ្ងៃទី០១-១០-២០០៧។បទល្មើសព្រហ្មទណ្ឌ និងទោសមានចែងក្នុង មាត្រា ២៥៥ នៃច្បាប់ភូមិបាល និង មាត្រា ៦២៦ និងមាត្រា ៦២៧ នៃក្រមព្រហ្មទណ្ឌ។

៧.ជនរងគ្រោះឈ្មោះ:[redacted] ហៀវ បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទាមទារសំណង និងជម្ងឺចិត្ត ជាប្រាក់ចំនួន ៣០.០០០.០០០ (សាមសិបលានរៀល) ។

៨.ជនជាប់ចោទឈ្មោះ:[redacted]ហ៊ាន អវត្តមាននាពេលសវនាការ ដោយជននេះបានស្លាប់ ដែលជាមូលហេតុនៃការរលត់បណ្តឹងអាជ្ញាតាមមាត្រា ៧ ចំណុច១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គប្បីតុលាការបញ្ឈប់ការចោទប្រកាន់។

៩.មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានការពារ:ឈ្មោះ: [redacted]ចេង និងឈ្មោះ:[redacted]



Scanned by CamScanner

ហ៊ានបានលួចលក់ដីរបស់ឈ្មោះ [redacted] ហៀវ ដែលជាដីរបស់ឈ្មោះ [redacted] ហៀវ បានកាន់កាប់តាំងពីឆ្នាំ ១៩៧៩ រហូតដល់ឆ្នាំ១៩៨៣ ដែលស្ថិតនៅភូមិអង្កោល ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប និងបានផ្លាស់ប្តូរទីលំនៅមកនៅស្រុកកំពង់ត្រាច ហើយបានឲ្យឈ្មោះ [redacted] សិដ្ឋ ជាក្មួយជួយមើលថែ និងបង្កបង្កើតផលលើដីនោះ។ឆ្នាំ២០០៧ ឈ្មោះ [redacted] ចេង និងឈ្មោះ [redacted] ហ៊ាន បានលួចលក់ដីនេះទៅឲ្យឈ្មោះ [redacted] ឆាយ ហៅពែក និងបានធ្វើលិខិតផ្ទេរសិទ្ធិ។ ក្រោយពីបានដឹងពីការលួចលក់ដីឈ្មោះ [redacted] ហៀវ បានដាក់ពាក្យបណ្តឹងមករយ្យការ។ ឈ្មោះ [redacted] ឆាយ ហៅពែក បានបដិសេធថាពុំបានយកឯកសារមកប្រើប្រាស់ តែពុំមានភស្តុតាងណាបញ្ជាក់ឡើយ។ឈ្មោះ [redacted] ឯម បានឆ្លើយគ្រប់ដំណាក់កាលថាខ្លួនពិតជាបានផ្តិតមេដៃជំនួសឈ្មោះ [redacted] សុន ពិតប្រាកដមែន ។ ពាក់ព័ន្ធ និងអង្គហេតុនេះជនជាប់ចោទឈ្មោះ [redacted] ចេង ឈ្មោះ [redacted] ហ៊ាន ឈ្មោះ [redacted] ឆាយ ហៅពែក និងឈ្មោះ [redacted] ឯម ពិតជាបានលួចលក់ និងក្លែងឯកសារសាធារណៈពិតប្រាកដមែន និងម្យ៉ាងទៀតមានលិខិតបញ្ជាក់របស់លោកមេឃុំនិងលោកមេភូមិ [redacted] សុន ចុះថ្ងៃទី០៤-១០-២០១០ និងចុះថ្ងៃទី២៨-០៥-២០១១ ដូចនេះខ្លួនជាមេធាវីការពារសិទ្ធិដើមបណ្តឹងសូមលោកចៅក្រមមេត្តាពិនិត្យ និងពិចារណាផ្តន្ទាទោស និងឲ្យតុលាការផ្តល់សំណងដូចក្នុងពាក្យបណ្តឹង។

-តំណាងរយ្យការបានធ្វើសេចក្តីសន្និដ្ឋានថ្លែងសុំ: ក្រោយពីបានស្តាប់ការសួរដេញដោលឃើញថា:អំពើប្រព្រឹត្តដូចមាននៅក្នុងដីកាសន្និដ្ឋានស្ថាពរ ដែលមានជនជាប់ចោទបួននាក់មានឈ្មោះ [redacted] ចេង ឈ្មោះ [redacted] ហ៊ាន ពីបទ លក់អចលនវត្ថុអ្នកដទៃ បទល្មើសព្រហ្មទណ្ឌ និងទោសមានចែងក្នុង មាត្រា ២៥៥ នៃច្បាប់ភូមិបាល និងឈ្មោះ [redacted] ឆាយ ហៅពែក .ឈ្មោះ [redacted] ឯម ពីបទក្លែងបន្លំលិខិត ប្រព្រឹត្តនៅភូមិអង្កោល ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប កាលពីថ្ងៃទី០១-១០-២០០៧។បទល្មើសព្រហ្មទណ្ឌ និងទោសមានចែងក្នុង មាត្រា ៦២៦ និងមាត្រា ៦២៧ នៃ ក្រមព្រហ្មទណ្ឌ។ជនជាប់ចោទឈ្មោះ [redacted] ចេង បានឆ្លើយបញ្ជាក់នៅសវនាការថាជនជាប់ចោទឈ្មោះ [redacted] ហ៊ាន បានស្លាប់ ហើយការស្លាប់របស់ជនជាប់ចោទជាការរលត់បណ្តឹងអាជ្ញា ដូចនេះនៅជនជាប់ចោទបីនាក់ដូចមាននៅក្នុងដីកាសន្និដ្ឋានស្ថាពរ អយ្យការតម្កល់ការចោទប្រកាន់ និង ទុកសិទ្ធិឲ្យចៅក្រមជំនុំជម្រះ ផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

-មេធាវីរបស់ជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារ: យោងតាមការពិនិត្យសំណុំរឿង និងការដេញដោល ដែលបានចោទប្រកាន់ឈ្មោះ [redacted] ឆាយ ហៅពែក ថាមានពិរុទ្ធភាពលើការក្លែងកាលពីថ្ងៃទី០១-១០-២០០៧ ការចោទប្រកាន់នេះពុំមានភស្តុតាងណាមួយដាក់បន្ទុកមកលើឈ្មោះ [redacted] ឆាយ ហៅពែក ទេ មូលហេតុដែលខ្ញុំបាទ លើដូច្នេះដោយអាជ្ញាធរដែនដី និងលោកមេភូមិបានអះអាងថា:ដីទំនាស់គឺជាដីដែលលោកយាយឈ្មោះ [redacted] ចេង ឈ្មោះ [redacted] ហ៊ាន ជានាក់កាន់កាប់តាំងពីឆ្នាំ១៩៧៩ ប្រទេសកម្ពុជាបានទទួលស្គាល់កម្មសិទ្ធិឯកជននៅឆ្នាំ១៩៨៩ ហើយឈ្មោះ [redacted] ចេង ឈ្មោះ [redacted] ហ៊ាន បានកាន់កាប់តាំងពីឆ្នាំ១៩៧៩ រហូតដល់ពេលលក់ ដែលអាចបញ្ជាក់បានថាឈ្មោះ [redacted] ចេង ឈ្មោះ [redacted] ហ៊ាន ជាភោគីស្របច្បាប់ ក្នុងនោះភោគីមានសិទ្ធិ លក់ ទិញ ផ្តល់មរតក នូវភោគៈរបស់ខ្លួនតាមចិត្តគ្មានអ្នកណាមកជំទាស់ ម្យ៉ាងទៀតខ្ញុំបាទបានដាក់ភស្តុតាងដែល លោកមេភូមិបានបញ្ជាក់ថាឈ្មោះ [redacted] ចេង ឈ្មោះ [redacted] ហ៊ាន ពិតជាបានកាន់កាប់ពិតប្រាកដមែន។ឈ្មោះ [redacted] ឆាយ ហៅពែក ដែលបានចោទប្រកាន់ថាក្លែងលិខិតមិនពិតទេ ដោយឈ្មោះ [redacted] ឆាយ ហៅពែក គ្រាន់តែមានទំនាក់ទំនងក្នុងការទិញលក់ និងមិនបានចូលរួមក្នុងការធ្វើលិខិតទេ ទាល់តែធ្វើលិខិតរួចទើបពួកគេប្រគល់មកឲ្យឈ្មោះ [redacted] ឆាយ ហៅពែក។ក្នុងរឿងនេះឈ្មោះ [redacted] ឆាយ ហៅពែកមិនបានចូលរួមប្រព្រឹត្ត និងគ្មានធាតុផ្សំបទល្មើស គ្រប់គ្រាន់ក្នុងការចោទប្រកាន់ ដូចនេះខ្ញុំបាទសូមសំណូមពរលោកចៅក្រមមេត្តាពិនិត្យទៅលើអង្គហេតុ និងអង្គច្បាប់ទាំងអស់ និងសម្រេចឲ្យឈ្មោះ [redacted] ឆាយ ហៅពែក បានរួចផុតពីបទចោទ។

គប្បីតុលាការពិចារណា ដូចមានក្នុងសំអាងហេតុដូចខាងលើ។

## សេចក្តីសម្រេច



Scanned by CamScanner

១.ផ្តន្ទាទោស

ក.ឈ្មោះ [redacted] ចេង ភេទស្រី អាយុ៥៥ឆ្នាំ ជាតិខ្មែរ មុខរបរជក ។ ទីកន្លែងកំណើតភូមិអង្កោល ឃុំភ្នំលាវ ស្រុកកំពង់ត្រាច ខេត្តកំពត។ទីលំនៅបច្ចុប្បន្ន [redacted] ស្រុកដំណាក់ចង្អើរ ខេត្តកែប។ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted](ស) ប្តីឈ្មោះ [redacted] មានកូន០១នាក់។ ទោសពីមុនគ្មាន។(ក្រៅឃុំ)

ដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ។ដោយទោសនេះឲ្យព្យួរការអនុវត្តទាំងមូល យោងតាមមាត្រា១០៨ .១០៧ នៃក្រមព្រហ្មទណ្ឌ។

ពីបទ លក់អចលនវត្ថុអ្នកដទៃ។ បទល្មើសព្រហ្មទណ្ឌ និងទោសមានចែងក្នុង មាត្រា ២៥៥ នៃច្បាប់ភូមិបាល។

ខ.ឈ្មោះ [redacted] ហ៊ាន ភេទស្រី អាយុ៧៥ឆ្នាំ ជាតិខ្មែរ។ទីកន្លែងកំណើតភូមិអង្កោល ឃុំភ្នំលាវ ស្រុកកំពង់ត្រាច ខេត្តកំពត។ទីលំនៅបច្ចុប្បន្ន [redacted] ស្រុកដំណាក់ចង្អើរ ខេត្តកែប។ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted](ស) ប្តីឈ្មោះ [redacted]) មានកូន០៤នាក់។ទោសពីមុនគ្មាន។

បញ្ឈប់ការចោទប្រកាន់ ពីបទ លក់អចលនវត្ថុអ្នកដទៃ។ តាមមាត្រា ៧ ចំណុច១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

គ.ឈ្មោះ [redacted] ឆាយ ហៅពែក ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ មុខរបរនេសាទ ។ ទីកន្លែងកំណើតភូមិអង្កោល សង្កាត់អង្កោល ខណ្ឌដំណាក់ចង្អើរ ក្រុងកែប។ទីលំនៅបច្ចុប្បន្ន [redacted] អង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប។ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] (រ) មានកូនបីនាក់។ ទោសពីមុនគ្មាន។(ក្រៅឃុំ)

ឃ.ឈ្មោះ [redacted] ឯម ភេទប្រុស អាយុ៦៨ឆ្នាំ ជាតិខ្មែរ មុខរបរសមាជិកក្រុមប្រឹក្សាឃុំ ។ ទីកន្លែងកំណើតភូមិអង្កោល ឃុំភ្នំលាវទី២ ស្រុកកំពង់ត្រាច ខេត្តកំពត។ ទីលំនៅបច្ចុប្បន្ន [redacted] ស្រុកដំណាក់ចង្អើរ ខេត្តកែប ។ ឪពុកឈ្មោះ [redacted] ស) ម្តាយឈ្មោះ [redacted](ស) ប្រពន្ធឈ្មោះ [redacted](ស) មានកូនបួននាក់។ ទោសពីមុនគ្មាន។(ក្រៅឃុំ)

ដាក់ពន្ធនាគារម្នាក់ៗកំណត់ ២ ឆ្នាំ ។ដោយទោសនេះឲ្យព្យួរការអនុវត្តទាំងមូល យោងតាមមាត្រា ១០៨ .១០៧ នៃក្រមព្រហ្មទណ្ឌ។

ពីបទ ក្លែងបន្លំលិខិត។ ប្រព្រឹត្តនៅភូមិអង្កោល ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប កាលពីថ្ងៃទី០១-១០-២០០៧។ បទល្មើសព្រហ្មទណ្ឌ និងទោសមានចែងក្នុង មាត្រា ៦២៦ និងមាត្រា ៦២៧ នៃក្រមព្រហ្មទណ្ឌ។

២.ឲ្យឈ្មោះ [redacted] ចេងឈ្មោះ [redacted] ហៅពែក និងឈ្មោះ [redacted] ឯម រួមគ្នាបង់សំណង និងជម្ងឺចិត្តជាប្រាក់មកឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៀវ ក្នុងម្នាក់ៗចំនួន ៣.០០០.០០០រៀល (បីលានរៀល)។ បណ្តឹងទាមទារលើសពីនេះ បដិសេធចោល។

៣.សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចេង ឈ្មោះ [redacted] ឆាយ ហៅពែក. ឈ្មោះ [redacted] ឯម និងដើមបណ្តឹងរដ្ឋប្បវេណី ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** — **ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា — ហត្ថលេខា និងត្រា

[redacted] [redacted]

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

កំពត ថ្ងៃទី[illegible] ខែមករា ឆ្នាំ២០១៤

**ក្រឡាបញ្ជី**

[redacted]



Scanned by CamScanner